# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង

ដើម្បីបញ្ចៀសនូវការដួលសន្លប់ជាយថាហេតុដែលបណ្តាលមកពីការកើនឡើងនូវកំដៅនារដូវប្រាំងនេះ ក្រសួងសូមណែនាំដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន ជាពិសេសសហគ្រាស គ្រឹះស្ថានកាត់ដេរសម្លៀកបំពាក់ និងដេរស្បែកជើងទាំងអស់អនុវត្តឱ្យបានហ្មត់ចត់នូវវិធានការដូចខាងក្រោម៖

១- ត្រូវមើលថែទាំ និងត្រួតពិនិត្យជាប្រចាំ និងបើកឱ្យដំណើរការប្រព័ន្ធបញ្ចេញបញ្ចូលខ្យល់នៅតាមអគារផលិតកម្មទាំងអស់ ឱ្យបានយ៉ាងហោចមួយម៉ោងមុនពេលអនុញ្ញាតឱ្យកម្មករនិយោជិតចូលបម្រើការងារស្របតាមប្រកាសលេខ១២៥ ស្តីពីការបញ្ចេញបញ្ចូលខ្យល់ និងការសំអាតបរិយាកាសក្នុងទីកន្លែងធ្វើការ។

២- ត្រូវដាក់ឱ្យមានឧបករណ៍វាស់ស្ទង់កំដៅ (សីតុណ្ហមាត្រ) នៅកន្លែងធ្វើការ ដើម្បីងាយស្រួលក្នុងតាមដានការវិវត្តនៃកំដៅ។

៣- ត្រូវរៀបចំទុកដាក់សម្ភារៈ កុំឱ្យបាំងប្រភពខ្យល់ចេញចូល។

៤- ត្រូវបើកបង្អួច ទ្វា ឱ្យបានធំទូលាយ ឬបន្ថែមកង្ហារបញ្ចូលខ្យល់ក្នុងអគារផលិតកម្មនៅពេលមានអាកាសធាតុក្តៅ។

៥- ត្រូវរៀបចំឱ្យមានប្រព័ន្ធស្រោចទឹកនៅលើដំបូលអគារផលិតកម្ម ឱ្យបានយ៉ាងហោចពីរដងក្នុងមួយថ្ងៃ ឬបន្ថែមសំណាញ់នៅលើដំបូលអគារផលិតកម្មដើម្បីកាត់បន្ថយកំដៅ។

៦- ត្រូវផ្តល់ទឹកស្អាតសម្រាប់បរិភោគឱ្យបានគ្រប់គ្រាន់ដល់កម្មករនិយោជិត ស្របតាមប្រកាសលេខ ០៥៤ ស្តីពីការផ្តល់ភេសជ្ជៈអនាម័យ។

៧- ត្រូវមើលថែទាំ និងត្រួតពិនិត្យជាប្រចាំប្រព័ន្ធបង្ការអគ្គិភ័យ និងសម្ភារៈការពាររួមនៅក្នុងអគារ សហគ្រាស គ្រឹះស្ថានឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងធានាថាប្រព័ន្ធ និងឧបករណ៍ទាំងនោះអាចដំណើរការបាន ក្នុងពេលមានគ្រោះអាសន្នកើតឡើងព្រមទាំងអនុវត្តតាមការណែនាំរបស់ក្រុមអធិការកិច្ចការងារ។

៨- ត្រូវរៀបចំឱ្យមានប្លង់សម្រាប់ជម្លៀសខ្លួន សញ្ញាការសុវត្ថិភាពនៅតាមបុស្តិ៍ការងារ និងការអប់រំបណ្តុះបណ្តាលកម្មករនិយោជិត ស្របតាមប្រកាសលេខ ១៧៦ ស្តីពីការអប់រំអនាម័យ និងបច្ចេកទេសសន្តិសុខការងារដល់កម្មករនិយោជិត ប្រតិភូបុគ្គលិក និងសហជីព។

៩- ចំពោះសហគ្រាស គ្រឹះស្ថានដែលមានប្រើប្រាស់សារធាតុគីមីងាយឆាបឆេះ ត្រូវរៀបចំឱ្យមានប្រព័ន្ធឆ្លើយតបគ្រោះអាសន្ន និងរក្សាទុកដាក់សារធាតុទាំងនោះឱ្យដាច់ដោយឡែកពីគ្នា និងដាច់ឆ្ងាយពីអគារផលិតកម្ម។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់នឹងអនុវត្តបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០១៧